ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
រដ្ឋបាលអន្តរាជ្ជានរដ្ឋបាល
លេខ ..... ម៉ោង 08:00
ថ្ងៃទី 24 ខែ កុម្ភៈ ឆ្នាំ 2023
ហត្ថ .....

អង្គការ បញ្ញាមូលនិធិអប់រំនៅកម្ពុជា

លេខ: ១៦០២-២០២៣ អបមអក

សូមគោរពជូន

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

កម្មវត្ថុ៖ របាយការណ៍សកម្មភាព របាយការណ៍ហិរញ្ញវត្ថុ និង បញ្ជីរគណនី របស់អង្គការ បញ្ញាមូលនិធិអប់រំនៅកម្ពុជា។

យោងតាម៖ លិខិតលេខ ២៥១២.សជណ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមកពីអង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជាមានកិត្តិយស សូមគោរពជំរាបជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** សូមទានជ្រាប ។

អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា បានចុះឈ្មោះក្នុងបញ្ជីរអង្គការមិនមែនរដ្ឋាភិបាលនៅក្រសួងមហាផ្ទៃតាមលិខិតលេខ ២៥១២ សជណ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៤។ ដើម្បីស្របទៅតាមច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ខ្ញុំបាទសូមគោរពរាយការណ៍ជូននូវរបាយការណ៍សកម្មភាព របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២និងបញ្ជីរាយឈ្មោះគណនីរបស់អង្គការដូចមានជូនភ្ជាប់មកជាមួយ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១១ រោជ ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០២៣

នាយកប្រតិបត្តិ

ត្រៃ សំបូរ

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការ បញ្ញាមូលនិធិអប់រំនៅកម្ពុជា
លេខ: ១៦០២-២០២៣ អបមអក

សូមគោរពជូន

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កម្មវត្ថុ: របាយការណ៍សកម្មភាព របាយការណ៍ហិរញ្ញវត្ថុ និង បញ្ជីរគណនីរបស់អង្គការ បញ្ញាមូលនិធិអប់រំនៅកម្ពុជា។
យោងតាម: លិខិតលេខ ២៥១២ សជណ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមកពីអង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា មានកិត្តិយស

សូមគោរពជំរាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី**
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

មេត្តាជ្រាបថា អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា បានចុះឈ្មោះក្នុងបញ្ជីរអង្គការមិនមែនរដ្ឋាភិបាលនៅក្រសួងមហាផ្ទៃតាមលិខិតលេខ ២៥១២សជណ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៤។ ដើម្បីស្របទៅតាមច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋភិបាល ខ្ញុំបាទសូមគោរពរាយការណ៍ជូននូវរបាយការណ៍សកម្មភាព របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២និងបញ្ជីរាយឈ្មោះគណនីរបស់អង្គការដូចមានជូនភ្ជាប់មកជាមួយ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃថ្ងៃព្រហស្បតិ៍ ១១ រោជ ខែ ហាយ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
សៀមរាប ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០២៣

នាយកប្រតិបត្តិ

ស្រ្តី សំបូរ

Scanned with CamScanner

ព្រះរាជណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

របាយការណ៍ប្រចាំ ឆ្នាំ២០២២
គម្រោងដែលអនុវត្តដោយផ្ទាល់
របស់ អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

សេចក្តីផ្តើម

នៅដើមឆ្នាំ២០២២ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានចាប់ផ្តើមបន្តគម្រោងរបស់ខ្លួននៅក្នុងឆ្នាំសិក្សាថ្មី ទោះបីមានបញ្ហាជំងឺ កូវីដ- ១៩(Covid-19) នៅតែបន្តក៏ដោយ តែគម្រោងបង្រៀនភាសារអង់គ្លេសរបស់យើងនៅតែបន្ត ព្រោះយើងនៅតែមានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និង សំភារៈ ពីម្ចាស់ជំនួយនានាទាំងក្នុង និង ក្រៅប្រទេស **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ បានខិតខំបំពេញការងារលើគម្រោងអប់រំសំរាប់កុមារនៅក្នុងតំបន់គោលដៅរបស់ខ្លួនរហូតទទួលបានលទ្ធផលដ៏ល្អ ដែលអង្គការសូមរាយការណ៍ជូនខាងក្រោម៖

ក. កម្មវិធីអប់រំភាសាអង់គ្លេស ដោយឥតគិតថ្លៃ

ក.១ សេចក្តីផ្តើម

នៅពេលសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបើកអោយដំណើរការឡើងវិញសារជាថ្មី **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានបន្តសកម្មភាពជួយបណ្តុះបណ្តាល ភាសា អង់គ្លេស ដល់កុមារកុមារី សិស្សានុសិស្ស នៅក្នុងសហគមន៍ជារៀងរាល់ថ្ងៃដោយឥតគិតថ្លៃ ដោយមានការជួយឧបត្ថម្ភពីមូលនិធិសប្បុរសធម៌អាយហើប (IHERB) តាមរយៈអង្គការ CCAFO

និងសប្បុរសជននានា នោះ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានបន្តគម្រោងអប់រំផ្នែកភាសាអង់គ្លេសដោយមិនយកកម្រៃ សម្រាប់សិស្សសាលាមកពី សាលាបឋមសិក្សា និងអនុវិទ្យាល័យ ស្ថិតក្នុងឃុំចំនួនបីគឺ ឃុំត្រពាំងធំ និង ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ហើយនិង ឃុំមួយផ្សេងទៀត គឺឃុំខ្វាស់ ស្រុកសូទ្រនិគមខេត្តសៀមរាប។

អាសយដ្ឋាន ៖ ផ្ទះលេខ.....ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008 Email: pagna.pcef.cambodia@gmail.com

ក.២ ស្ថិតិគ្រូ និង សិស្ស

នៅដើមខែមករាឆ្នាំ ២០២២ កម្មវិធីសិក្សាសម្រាប់ឆ្នាំថ្មីបានចាប់ផ្តើម យើងមានគ្រូសរុបចំនួន៨នាក់ (ស្រី៥នាក់) ហើយនៅចុងឆ្នាំ២០២២នេះដែរក៏មានគ្រូចំនួន៣នាក់ (ស្រី២នាក់)បានដាក់ពាក្យសុំឈប់ពីការងារ ដោយសារតែបញ្ហាផ្ទាល់ខ្លួន។

ក្នុងឆ្នាំ២០២២នេះយើងមានសិស្សចំនួន៦៤៤នាក់ (សិស្សស្រីចំនួន៣៨៣នាក់) ចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើង។

ឆ្នាំ២០២២ កម្មវិធីបង្រៀនទាំងអស់ត្រូវបានបន្តទៅលើស្ថានភាពជាក់ស្តែងជាមួយសិស្សជាច្រើនដែលបានចូលរួម។

ក.៣ ទីតាំងទី១ នៅ ភូមិល្វា ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប

យើងខ្ញុំបានធ្វើការបែងចែកសិស្សទៅជា១៧ក្រុម ហើយសម្រាប់ថ្នាក់ពេលព្រឹកមាន៨ថ្នាក់ ជាមួយការបង្រៀនចាប់ផ្តើមពីម៉ោង ៧.៣០ព្រឹក ដល់ម៉ោង១០.៣០ព្រឹក (មួយថ្នាក់ត្រូវរៀន ១ម៉ោងកន្លះ)។ សំរាប់ថ្នាក់ពេលរសៀលមានចំនួន ៥ថ្នាក់ ហើយមួយថ្នាក់ត្រូវរៀន ១ម៉ោងកន្លះដូចគ្នា ដោយចាប់ពីម៉ោង ១រសៀល ដល់ម៉ោង៤ រសៀល។ សំរាប់ថ្នាក់ពេលយប់មានចំនួន ៨ថ្នាក់ ហើយមួយថ្នាក់ត្រូវរៀន ១ម៉ោង ដោយចាប់ពីម៉ោង ៦យប់ ដល់ម៉ោង៨យប់។

នៅទីតាំងទី១ ក្នុង ភូមិល្វា ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដើមឆ្នាំ២០២២ យើងមានសិស្សចំនួន ៣៨៣នាក់ (សិស្សស្រីចំនួន ២៣៨នាក់) ចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើង ប៉ុន្តែមកដល់ចុងឆ្នាំ២០២២ គម្រោងយើងមានសិស្សនៅសល់ត្រឹមតែ ៣៥១នាក់ ស្រីចំនួន ២១៩នាក់។

ចំនួនសិស្សដែរបោះបង់សាលាចំនួន ៣២នាក់ ស្រី ១៩នាក់។

ក.៤ ទីតាំងទី២ នៅភូមិគោកក្តុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប

យើងខ្ញុំបានធ្វើការបែងចែកសិស្សជា៩ក្រុម ហើយសម្រាប់ថ្នាក់ពេលព្រឹកមាន៣ថ្នាក់ ជាមួយការបង្រៀនចាប់ផ្តើមពីម៉ោង ៨.០០ព្រឹក ដល់ម៉ោង១១.៣០ព្រឹក (មួយថ្នាក់ត្រូវបង្រៀន ១ម៉ោង)។ សំរាប់ថ្នាក់ពេលរសៀលមានចំនួន ៣ថ្នាក់ ហើយមួយថ្នាក់ត្រូវបង្រៀន ១ម៉ោង ដោយចាប់ពីម៉ោង ១រសៀល ដល់ម៉ោង៥ រសៀល។ សំរាប់ថ្នាក់ពេលយប់មានចំនួន ៣ថ្នាក់ ហើយមួយថ្នាក់ត្រូវបង្រៀន ១ម៉ោងផងដែរ ដោយចាប់ពីម៉ោង ៥យប់ ដល់ម៉ោង៨យប់។

នៅទីតាំងទី២ ក្នុង ភូមិគោកក្តុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដើមឆ្នាំ២០២២ យើងមានសិស្សចំនួន ២៤១នាក់ (ស្រីចំនួន ១៥០នាក់) បានចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើងប៉ុន្តែមកដល់ចុងឆ្នាំ២០២២ គម្រោងយើងមានសិស្សនៅសល់ត្រឹមតែ ១៩៥នាក់ ស្រីចំនួន ១២៩នាក់។

សិស្សដែរបោះបង់សាលាចំនួន ៤៦នាក់ ស្រី ២១នាក់ ភាគច្រើនគឺជាសិស្សដែលក្រីក្រ ដែលឪពុកម្តាយទាមទារអោយជួយធ្វើការងាររកប្រាក់ចំនូលប្រចាំថ្ងៃ។

ទីតាំងទី២ នៅភូមិគោកក្តុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប							
ឈ្មោះគ្រូ	កាលវិភាគបង្រៀន	ម៉ោង	នៅសាលារដ្ឋថ្នាក់ទី	កំរិតសៀវភៅដែលត្រូវរៀន	ចំនួនសរុប	ស្រី	អាយុ
ណូត ស្រីល័ក្ខ	ព្រឹក	8.00-9.00	1+4	ABC	33	18	6 ទៅ 8 ឆ្នាំ
ណូត ស្រីល័ក្ខ		9.00-10.00	3+5	Starter	19	8	8 ទៅ 10 ឆ្នាំ
ឡេង សូវិន		10.00-11.30	6+7	Family &Friends 1	8	5	10 ទៅ 13 ឆ្នាំ
លាង សុនាត	រសៀល	1.00-2.00	1+4	ABC	38	25	6 ទៅ 8 ឆ្នាំ
លាង សុនាត		2.00-3.30	3+5	Starter	20	12	8 ទៅ 10 ឆ្នាំ
ឡេង សូវិន		3.30-5.00	6+7	Family &Friends 1	18	11	10 ទៅ 13 ឆ្នាំ
លាង សុនាត	យប់	5.00-6.00	8+10	Family &Friends 2	36	20	13 ទៅ 15 ឆ្នាំ
ឡេង សូវិន		6.00-7.00	8+10	Family &Friends 2	44	35	13 ទៅ 15 ឆ្នាំ
ឡេង សូវិន	យប់	7.00-8.00	9+11	Family & Friends 3	25	16	15 ទៅ 17 ឆ្នាំ
				សរុបនៅភូមិគោកក្តុល	241	150	
				សិស្សបោះបង់សាលា	46	21	

ក.៥ សកម្មភាពចូរចៅរបស់ អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

សកម្មភាពបង្រៀនភាសាតាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានបញ្ចូលក្នុងមេរៀនគ្រប់ថ្នាក់នីមួយៗ

ក្នុងគោលបំណងដើម្បីឲ្យសិស្សទាំងអស់បានស្តាប់, ទស្សនាកំរងមេរៀន និងហាត់បញ្ចេញសំលេងឲ្យបានត្រឹមត្រូវ។

យើងខ្ញុំបានខិតខំទំនាក់ទំនងរកគ្រូបង្រៀនស្ម័គ្រចិត្តជាច្រើនមកពីតាមប្រទេសផ្សេងៗគ្នាដើម្បីជួយបង្រៀននិងផ្តល់ឱកាសឱ្យសិស្សបានហ្វឹកហាត់អភិវឌ្ឍសមត្ថភាពផ្នែកស្តាប់និងបញ្ចេញសំលេងជាមួយគ្រូបរទេសដោយផ្ទាល់ផ្ទាល់ផងដែរ។

ក្រុមការងារយើងខ្ញុំនៅតែបន្តយកចិត្តទុកដាក់ទៅលើអនាម័យ មុនពេលចូលរៀន តាមការណែនាំរបស់ក្រសួងអប់រំ និង ក្រសួងសុខាភិបាល ដើម្បីការពារជំងឺ កូវីដ-១៩ (Covid-19)។

លោកគ្រូអ្នកគ្រូបានបង្រៀនសិស្សតាមកាលវិភាគដែលសាលាបានកំណត់ពេលវេលា ទៅតាមម៉ោងសិស្សដែលបានកំណត់។

- **ផ្នែកទំនាក់ទំនង និង ចូលរួម**

អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា យើងខ្ញុំបានចូលរួមរាល់សកម្មភាពជាមួយអាជ្ញាធរដូចជា៖ ការសំអាតបរិស្ថានចូលរួមប្រជុំប្រចាំខែ និងប្រជុំ នានា ព្រមទាំងចូលរួមសហការរាល់សកម្មភាពផ្សេងៗជាច្រើនទៀតទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិតាមតែអាចធ្វើទៅបាន។

យើងមានការប្រជុំជាមួយបុគ្គលិកជារៀងរាល់ខែ ហើយក៏មានការចូលរួមប្រជុំជាមួយអង្គការសង្គមស៊ីវិល និងអង្គភាពផ្សេងៗទៀតផងដែរ។

ម៉្យាងទៀតខាង **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** របស់យើងក៏មានការបណ្តុះបណ្តាលគ្រូបង្គោល(teachers training course) ដើម្បី អភិវឌ្ឍន៍សមត្ថភាពគ្រូបង្គោលអំពីការបង្រៀនសិស្សអោយមានភាពរីកចំរើនផងដែរ។

ក.៦ លទ្ធផលសម្រេចបាន

គម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ថ្វីត្បិតតែពួកគេរៀនមិនសូវបានជិតដល់ដូចកាលឆ្នាំមុនៗ ប៉ុន្តែពួកគេជាង៨0%បានប្រលងជាប់និងបានបន្តទៅថ្នាក់កម្រិតខ្ពស់ជាងមុនគួរអោយសរសើរ លើសពីនេះទៅទៀតយើងឃើញថាមាតាបិតាសិស្សក៏មានការចូលរួមច្រើនផងដែរ នៅពេលដែលអង្គការត្រូវការជំនួយពីពួកគាត់ម្តងៗ។

ថ្វីត្បិតតែមានការប្រកាសពីរាជរដ្ឋាភិបាលកម្ពុជា និងក្រសួង សុខាភិបាល ក៏ដូចជា ក្រសួងអប់រំឲ្យពួកយើងបានចូលរៀនវិញជាធម្មតាក៏ដោយ ប៉ុន្តែ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** នៅតែបន្តអនុវត្តឲ្យបានខ្ជាប់ខ្ជួនអំពីការសម្អាត និងការធ្វើអនាម័យ ដើម្បីការពារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19) យើងខ្ញុំបាននាំគ្នារក្សាអនាម័យយ៉ាងម៉ឺងម៉ាត់បំផុតតាមតែអាចធ្វើទៅបាន។

ខ. កម្មវិធីផ្តល់អំណោយដល់សិស្សក្រីក្រខ្វះខាត

ខ.១ គោលបំណង

ជួយរកជំនួយឧបត្ថម្ភដើម្បីទ្រទ្រង់ដល់គ្រួសារសិស្សក្រីក្រដែលត្រូវការជំនួយដើម្បីជួយសម្រាលទុក្ខលំបាកក្នុងជីវភាពរបស់ពួកគេដើម្បីបន្តការសិក្សាពេលបច្ចុប្បន្ន និងដើម្បីអនាគតរបស់ពួកគេផងដែរ។

ខ.២ បេសកកម្ម

- **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ព្យាយាមស្វះស្វែងស្នើរសុំទៅសប្បុរសជននានា ដើម្បីរកជំនួយជាសម្ភារៈសិក្សា មធ្យោបាយធ្វើដំណើរ ក៏ដូចជាសម្ភារៈផ្សេងៗទៀតដើម្បីជួយសម្រួលដល់ជីវភាពរបស់ពួកគាត់។
- ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដើម្បី ធ្វើការរួមគ្នានិងចុះទៅជួបផ្ទាល់ជាមួយគ្រួសារ និង សិស្សក្រីក្រពិតប្រាកដដែលកំពុងតែត្រូវការជំនួយជាចាំបាច់បំផុត។

ខ.៣ លទ្ធផលសម្រេចបាន

ដោយការស្នើរសុំពី **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ទៅម្ចាស់ជំនួយនានា ដើម្បីជួយគាំទ្រគម្រោងរបស់យើងដូច្នេះក៏មានអ្នកជួយឧបត្ថម្ភ ដូចខាងក្រោម៖

1. អ្នកស្រី វើរ៉ូនីកា (Veronika) អ្នកសម្របសម្រួលរបស់ អាយហើប (IHERB) បានឧបត្ថម្ភការចំណាយប្រតិបត្តិការទាំងអស់របស់ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ជារៀងរាល់ឆ្នាំតាមរយ **អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា** Cambodian Children's Advocacy Foundation ។
2. លោកស្កុត នីសុន (Scott Neeson) ជាស្ថាបនិករបស់ **អង្គការ មូលនិធិកុមារកម្ពុជា** បានជួយឧបត្ថម្ភស្បែកជើងកីឡាចំនួន១៣៦គូរមក **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ដើម្បីចែកដល់កុមារក្រីក្រ និងខ្វះខាតសម្រាប់ពាក់ទៅរៀននិងលេងកីឡា។
3. លោកស្កុត នីសុន (Scott Neeson) ជាស្ថាបនិករបស់ **អង្គការ មូលនិធិកុមារកម្ពុជា** បានជួយឧបត្ថម្ភកង់ចំនួន២០គ្រឿងមក **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ដើម្បីចែកដល់កុមារក្រីក្រ និងខ្វះខាតមធ្យោបាយធ្វើដំណើរទៅសិក្សា ។

4. លោកស្កុត នីសុន (Scott Neeson) ជាស្ថាបនិករបស់ **អង្គការ មូលនិធិកុមារកម្ពុជា** ក៏បានជួយឧបត្ថម្ភកាបូបរៀនចំនួន 333 បន្ថែមទៀតដល់ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ដើម្បីចែកដល់សិស្ស ក្រីក្រ សម្រាប់ឆ្នាំសិក្សាថ្មី ២០២២-២០២៣នេះផងដែរ។

5. អ្នកស្រីសាន់ឌី ព្រមទាំងក្រុមការងារបាននាំយកសម្ភារៈ សិក្សាចំនួន 400 ឈុតមកចែកដល់សិស្សានុសិស្សរបស់យើងចំនួន400នាក់ផងដែរ ។

<u>ជាមួយគ្នានេះផងដែរ អង្គការក៏បានអនុវត្តសកម្មភាពមួយចំនួនទៀត រួមមាន៖</u>

- ការបណ្តុះបណ្តាល និងការបំប៉នបច្ចេកទេសបន្ថែមទៀតដល់គ្រូបង្គោល។
- អង្គការបានបន្តបញ្ជូនគ្រូ ២នាក់បន្ថែមទៀតទៅបន្តការសិក្សាជំនាញផ្នែកអក្សរសាស្ត្រភាសាអង់គ្លេស(ឆ្នាំទី៤) និងផ្នែករដ្ឋបាលសាធារណៈម្នាក់ (ឆ្នាំទី4) នៅសាកលវិទ្យាល័យ(CUS ខេត្តសៀមរាប) ។
- គ្រូ ៣នាក់ផ្សេងទៀតបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រលើជំនាញផ្នែកអក្សរសាស្ត្រភាសាអង់គ្លេសនៅសាកលវិទ្យាល័យ(CUS ខេត្តសៀមរាប) ផងដែរ។
- យើងមានការប្រជុំរវាងគ្រូៗហើយនិងអាណាព្យាបាលសិស្សពីរដងក្នុងមួយឆ្នាំ។
- ការប្រជុំប្រចាំខែជាមួយគ្រូៗជារៀងរាល់ខែ។
- **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានជួយឧបត្ថម្ភសម្ភារៈសិក្សាមានដូចជា: សៀវភៅ ប៊ិច ខ្មៅដៃ ប្រដាប់ចិតខ្មៅដៃ ជ័រលុប និងសម្ភារៈផ្សេងៗជាច្រើនទៀតដល់កុមារទាំងអស់នោះ ។

គ. <u>បញ្ហាប្រឈម និងដំណោះស្រាយ</u>

គ.១. បញ្ហាប្រឈម

- ខ្វះថវិការសាងសង់បន្ទប់រៀន និង ជួលគ្រូបន្ថែម ព្រោះដោយសារតែមានកំណើនសិស្សកើនឡើងជារៀងរាល់ឆ្នាំ ដែលជាហេតុធ្វើអោយយើងខ្វះថ្នាក់រៀន និងខ្វះគ្រូបង្គោលបន្ថែម។
- សមត្ថភាពគ្រូតាមមូលដ្ឋាននៅមានកម្រិត យើងខ្ញុំនៅតែត្រូវការអ្នកជួយឧបត្ថម្ភសម្រាប់ការសិក្សារបស់គ្រូៗបន្ថែមទៀត។

គ.២. <u>ដំណោះស្រាយ</u>

-យើងខ្ញុំនៅតែស្វែងរកសប្បុរសជនដើម្បីជួយឧបត្ថម្ភថ្លៃសាងសង់បន្ទប់រៀនបន្ថែមក៏ដូចជារកជំនួយឧបត្ថម្ភដើម្បីជួលគ្រូបន្ថែមទៀតផងដែរ។

-អង្គការរបស់យើងខ្ញុំសូមធ្វើការអំពាវនាវដល់បងប្អូនសប្បុរសជន ក្នុងនិងក្រៅប្រទេសមេត្តាជួយឧបត្ថម្ភគាំទ្រ ដើម្បីអោយគម្រោងយើងខ្ញុំបានបន្តជួយបង្រៀនដល់កុមារក្រីក្រតាមជនបទបន្តទៀត។

-យើងខ្ញុំនៅតែបន្តរកវិធីសាស្ត្រដើម្បីជួយគ្រូៗមូលដ្ឋានអោយមានសមត្ថភាពប្រសើរឡើងតាមតែអាចធ្វើបាន។

-យើងខ្ញុំនិងខិតខំព្យាយាមផ្សព្វផ្សាយទៅទូទាំងពិភពលោកដើម្បីជួយរកគ្រូស្ម័គ្រចិត្តមកពីប្រទេសផ្សេងៗដើម្បីជួយពង្រឹងដល់សិស្សក៏ដូចជាជួយពង្រឹងសមត្ថភាពគ្រូក្នុងតំបន់អោយកាន់តែប្រសើរឡើង។

ឃ. សន្និដ្ឋាន

ទោះបីជាជួបប្រទះនៅបញ្ហាប្រឈមមួយចំនួន ក៏ដោយក៏គម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** នៅតែមានដំណើរការជាបណ្តើរៗ ពីមួយថ្ងៃទៅមួយថ្ងៃកំពុងមានសន្ទុះទៅមុខសំដៅទៅជួយដល់ការអភិវឌ្ឍន៍ធនធានមនុស្សជំនាន់ថ្មីរបស់យើងសម្រាប់បន្តវេននាពេលអនាគត ក៏ដូចជាការចូលរួមចំណែកដ៏តូចមួយក្នុងការអភិវឌ្ឍន៍ជាមួយនិងប្រមុខរដ្ឋាភិបាលផងដែរ។

ថ្ងៃព្រហស្បតិ៍ ១១ រោជ ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០២៣

នាយកប្រតិបត្តិ

ស្រី សំបូរ

អាសយដ្ឋាន ៖ ផ្ទះលេខ.....ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ ស្រុកក្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008 Email: pagna.pcef.cambodia@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២

មូលនិធិដើមគ្រា			**$ 5.51**
ទទួលបានពីម្ចាស់ជំនួយ ដូចជា៖			
១. មូលនិធិអាយហើប (iHerb Charitable Foundation)			$ 17,969.00
២. អង្គការ កុមារកម្ពុជា (CCF)			$ 1,595.00
៣. QR Code Transferred (Canadia Bank)			$ 52.43
៤.ការបរិច្ចាគផ្ទាល់ដៃ (Hand donation)			$ 461.71
៥. ប្រាក់ ការពីធនាគាទាំងពីរ អេស៊ីលីដា -កាណាឌីយ៉ា (Bank Interest income)			$ 1.34
៧. ជំនួយពីសប្បុរសជនផ្សេងៗ			$ 320.00
មូលនិធិសរុប			**$ 20,404.99**

ការចំណាយលើគំរោងនីមួយៗ

១. គម្រោងថ្នាក់ភាសាអង់គ្លេស		$ 15,378.91
២. គម្រោងបំប៉ន់ជំនាញគ្រូៗនៅសកលវិទ្យាល័យ		$ 1,006.54
៣. គម្រោងអាហារសម្រន់ប្រជុំអាណាព្យាបាលសិស្ស និង ប្រជុំនានា		$ 291.94
៤. គម្រោងធានារ៉ាប់រងសុខភាព និង សោធន៍នីវត្ត បុគ្គលិក		$ 538.17
៥. ថ្លៃទឹក ភ្លើង និង អ៊ីនធឺណិត		$ 399.99
៦. គម្រោងជួសជុល និងសាងសង់		$ 1,895.54
៧. ចំណាយផ្សេងៗ		$ 716.87
សរុបចំណាយ		**$ 20,227.96**
បានឃើញ និង ឯកភាព	ប្រាក់នៅសល់ចុងគ្រា	**$ 177.03**

ថ្ងៃព្រហស្បតិ៍ ១១ រោជ ខែ មាឃ ឆ្នាំខាលចត្វាស័ក ព.ស ២៥៦៦
សៀមរាប ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២៣

នាយកប្រតិបត្តិ

ស្រី សំអូរ

អ្នកធ្វើរបាយការណ៍

ជិម ចំរុង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

លេខ: ១៦០២-២០២៣ អ.ប.ម.អ.ក

ព័ត៌មានអំពីគណនី

នៅក្នុងឆ្នាំ២០២២ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** មានគណនីធនាគារចំនួនពីរ សម្រាប់ទទួលជំនួយ និងទូទាត់រាល់ការចំណាយក្នុងប្រតិបត្តិការរបស់អង្គការដែលអនុវត្តដោយផ្ទាល់ ៖

១- ធនាគារ អេស៊ីលីដា

២- ធនាគារ កាណាឌីយ៉ា

ឈ្មោះគណនី	លេខគណនី	មានទឹកប្រាក់នៅចុងគ្រាចំនួន
Cambodian Education Fund	34750214532411	74.27 ដុល្លារ (ស្មើរនិង 305621.05 រៀល)
Cambodian Education Fund	0080000657119	142.96 ដុល្លារ (ស្មើរនិង 588280.4 រៀល)

ថ្ងៃព្រហស្បតិ៍ ១១ រោជ ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០២៣

នាយយកប្រតិបត្តិ

ស្រី សំបូរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៦៩១៤ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ៥ ឆ្នាំ ២០១៤

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ជម្រាបមក
លោក ស្រី សំបូ ប្រធានអង្គការបញ្ជាមូលនិធិអប់រំនៅកម្ពុជា

កម្មវត្ថុ : អំពីការសុំចុះបញ្ជីរបស់ ***អង្គការបញ្ជាមូលនិធិអប់រំនៅកម្ពុជា*** នៅក្រសួងមហាផ្ទៃ។
យោង : លិខិតលេខ ***001*** ចុះថ្ងៃទី ***២៥*** ខែ ***សីហា*** ឆ្នាំ ***២០១៤*** ស្តីពីការសុំចុះបញ្ជីរបស់ ***អង្គការបញ្ជាមូលនិធិអប់រំនៅកម្ពុជា***។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី ***អង្គការបញ្ជាមូលនិធិអប់រំនៅកម្ពុជា*** ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលនៅភូមិ ***ល្វា*** ឃុំ ***ត្រពាំងធំ*** ស្រុក ***គ្រាំសារគាម*** ខេត្ត ***សៀមរាប*** នោះហើយ។ ***អង្គការបញ្ជាមូលនិធិអប់រំនៅកម្ពុជា*** ត្រូវអនុវត្តតាមលក្ខន្តិក:ដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាអង្គការអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ មិនធ្វើជាឧបករណ៍គណបក្សនយោបាយ និងមិនស្វែងរកប្រាក់កម្រៃជាឯកជន។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន អង្គការបញ្ជាមូលនិធិអប់រំនៅកម្ពុជា ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីឱ្យបានត្រឹមត្រូវតាមច្បាប់។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន និងសហការអនុវត្តតាមការគួរ។

ស.រដ្ឋមន្ត្រី
អនុលេខាធិការ

ប៊ុន លឹម

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តសៀមរាប
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ